# មតិយោបល់របស់អង្គការសង្គមស៊ីវិល
# សម្រាប់ជាធាតុចូល ដើម្បីសម្រួលដល់នីតិវិធី នៃការធ្វើផែនទីបឋម
# សម្រាប់ដំណើរការចុះបញ្ជីដីសមូហភាពសហគមន៍
# ជនជាតិដើមភាគតិចនៅកម្ពុជា

## សេចក្តីផ្តើម

ឯកសារគោលជំហរនេះ ត្រូវបានរៀបចំឡើង ក្នុងគោលបំណងសំខាន់គឺ ចង់ឃើញការឯកភាពគ្នារវាងស្ថាប័នពាក់ព័ន្ធ លើដំណើរការនៃការធ្វើផែនទីបឋមដែលមានលក្ខណៈសាមញ្ញ ងាយស្រួល និងមានប្រសិទ្ធភាព ជាផ្នែកមួយដ៏សំខាន់នៃដំណើរការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច (រាប់ទាំងសហគមន៍ចាស់ដែលមិនទាន់ធ្វើផែនទីបឋម)។ ដោយយល់ឃើញបែបនេះ ទើបមានការរៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងស្តីពីបទពិសោធន៍នៃការធ្វើផែនទីបឋមក្នុងដំណើរការចុះបញ្ជីដីសមូហភាពជនជាតិដើមភាគតិច កាលពីថ្ងៃទី ២-៣ ខែកក្កដា ឆ្នាំ ២០២០ កន្លងមកថ្មីៗនេះ ដោយមានការចូលរួមពីសំណាក់តំណាងក្រសួងចំនួនបីរួមមាន៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងមហាផ្ទៃ និងក្រសួងអភិវឌ្ឍន៍ជនបទ ព្រមទាំងតំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលធ្វើការជាមួយជនជាតិដើមភាគតិច សរុបចំនួន ២៩នាក់ ។ ឯកសារគោលជំហរនេះ មានការរៀបរាប់ជាលំដាប់លំដោយនូវសាវតានៃការចុះបញ្ជីដោយសង្ខេប ភាពចាំបាច់នៃការធ្វើផែនទីបឋម ក្របខ័ណ្ឌច្បាប់ បទពិសោធន៍ និងការប្រឈម ជំហរដែលស្នើឡើង និងសេចក្តីសន្និដ្ឋាន។

## សាវតាសង្ខេបនៃការចុះបញ្ជីដីសមូហភាពសហគមន៍ និងភាពងាយរងគ្រោះ

### ប្រវត្តិសង្ខេបនិងសមិទ្ធផលនៃការចុះបញ្ជីដីសមូហភាព

គេទទួលស្គាល់ជាទូទៅថា មានក្រុមជនជាតិដើមភាគតិចចំនួន ២៤ក្រុម នៅកម្ពុជា។ សិទ្ធិជនជាតិដើមភាគតិចនៅកម្ពុជា ជាពិសេស សិទ្ធិទទួលបានធនធានដីធ្លី ត្រូវបានទទួលស្គាល់ជាផ្លូវការ នៅក្នុងច្បាប់ភូមិបាល ២០០១ ។ លើសពីនេះទៀត អនុក្រឹត្យលេខ ៨៣ (២០០៩) ស្តីពី "នីតិវិធីនៃការចុះបញ្ជីដីសមូហភាព" ដែលស្របទៅនឹងច្បាប់ព្រៃឈើ (២០០២) និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ (២០០៨) បង្ហាញនូវគោលការណ៍ណែនាំលម្អិតស្តីពី វិធីដែលជនជាតិដើមភាគតិច អាចចុះបញ្ជីដីសមូហភាពសហគមន៍បាន។ នៅក្នុងអំឡុងដើមទសវត្សរ៍ ២០១០ គម្រោងផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព ត្រូវបានធ្វើការសាកល្បងនៅក្នុងសហគមន៍ជនជាតិដើមភាគតិចចំនួន ២ នៅក្នុងខេត្តរតនគិរី និងមួយទៀតនៅខេត្តមណ្ឌលគិរី ។ សហគមន៍ទាំងនេះទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព ក្នុងរយៈពេលចន្លោះពីឆ្នាំ

២០១១ និង ២០១៣។ ជាទូទៅ ដំណើរការចុះបញ្ជីត្រូវឆ្លងកាត់ដំណាក់ការបីសំខាន់គឺ ១) ការទទួលស្គាល់អត្តសញ្ញាណពីសំណាក់ក្រសួងអភិវឌ្ឍន៍ជនបទ ដែលមកដល់ពេលនេះ បាន ១៥០ គិតត្រឹមខែវិច្ឆិកា ឆ្នាំ ២០១៩ ២) ការចុះជានីតិបុគ្គលដោយក្រសួងមហាផ្ទៃ ដែលគិតមកដល់ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០២០ នេះ បានចំនួន ១៥០សហគមន៍ និង ៣) ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលគិតមកដល់ដំណាច់ខែធ្នូ ឆ្នាំ ២០១៩ បានចំនួន ៣០ សហគមន៍ ក្នុងចំណោម សហគមន៍ជនជាតិដើមភាគតិចដែលបានដាក់ពាក្យស្នើសុំចំនួន ៦៨ ។ ដោយឡែក នៅចន្លោះដំណាក់កាលទី ២ និងទី ៣ ជាដំណើរការទាក់ទងការធ្វើផែនទីបឋម ដែលគេហៅថាជាដំណាក់ការ ២.៥ ដែលគេទទួលស្គាល់ថា អង្គការសង្គមស៊ីវិលបានដើរតួនាទីសំខាន់រួមជាមួយមន្ត្រីនៅមូលដ្ឋាន ។

**ភាពងាយរងគ្រោះនៃសហគមន៍ជនជាតិដើមភាគតិច**

បន្ទាប់ពីបានអនុវត្តការចុះបញ្ជីដីសមូហភាពជនជាតិដើមភាគតិច ជិតមួយទសវត្សមកនេះ ប្រទេសកម្ពុជាធ្វើបានល្អជាងប្រទេសផ្សេងទៀតនៅតំបន់អាស៊ីអគ្នេយ៍ ជាពិសេសគឺ ការទទួលស្គាល់សិទ្ធិរបស់ជនជាតិដើមភាគតិច ក្នុងការទទួលបាននិងប្រើប្រាស់ធនធានដីធ្លី។ ទោះយ៉ាងណាក្តី ស្ថាប័នពាក់ព័ន្ធបានមើលឃើញថា ជាទូទៅ ដំណើរការចុះបញ្ជីដីកម្មសិទ្ធិសមូហភាព គួរតែមានការកែសម្រួលឱ្យមានភាពសាមញ្ញ ងាយស្រួល និងមានប្រសិទ្ធភាព ។ ជាក់ស្តែង កន្លងមកមានការចំណាយពេលវេលាច្រើនទាក់ទងទៅនឹងការងារបច្ចេកទេសដែលពាក់ព័ន្ធការរៀបចំផែនទីបឋម តែងតែមានការយឺតយ៉ាវ ជាពិសេស ចំពោះការសម្រេចចិត្តលើតំបន់ត្រួតស៊ីគ្នាក្នុងតំបន់ការពារធម្មជាតិ ព្រោះតែពុំទាន់មានការកំណត់តំបន់ទាំង៤ប្រភេទ នៅក្នុងតំបន់ការពារធម្មជាតិនៅឡើយ។ ក្នុងខណៈដែលមានការអូសបន្លាយហើយ និងវិធានការការពារបណ្តោះអាសន្នពុំមាន ឬមិនបានជំរុញការអនុវត្ត សហមគន៍ជនជាតិដើមភាគតិចកាន់តែទទួលរងគ្រោះថែមទៀត ដោយសារសម្ពាធពីកត្តាខាងក្រៅពោលគឺ ការផ្លាស់ប្តូរសេដ្ឋកិច្ច សង្គម និងបច្ចេកវិទ្យាឆាប់រហ័ស នាំឱ្យជនជាតិដើមភាគតិច បាននឹងកំពុងលក់ដីជាហូរហែរ ព្រមទាំងចង់បានដីកម្មសិទ្ធិឯកជន ដើម្បីងាយស្រួលក្នុងប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ ដូចជាដាក់បញ្ចាំនៅធនាគារជាដើម។ ការប្រែប្រួលបែបនេះ វាមានដំណើរផ្ទុយគ្នាទៅនឹងច្បាប់ និងអនុក្រឹត្យពាក់ព័ន្ធទៅនឹងសហគមន៍ជនជាតិដើមភាគតិច ក៏ដូចជា ការចង់បានជាទូទៅក្នុងការរស់នៅបែបសមូហភាពដែលពឹងអាស្រ័យតែទៅលើដី និងធនធានធម្មជាតិដែលមាននៅក្នុងតំបន់ដែលខ្លួនរស់នៅ។

## ភាពចាំបាច់នៃការធ្វើផែនទីបឋម

កន្លងមក ជាផ្នែកមួយនៃដំណាក់កាល ២.៥ ការតម្រូវឱ្យធ្វើផែនទីបឋមជាតម្រូវការជាក់ស្តែងនៃមន្ត្រីភូមិបាល ដែលប្រហែលជាត្រូវបានធ្វើឡើងយោងតាមមាត្រា ៨ នៃអនុក្រឹត្យលេខ ៨៣ ប៉ុន្តែពុំមានច្បាប់ ឬគោលការណ៍ណាមួយជាក់លាក់ជាងនេះសម្រាប់ការតម្រូវឱ្យធ្វើនោះដែរ។ វាក៏ជាជំហានមួយដែលមិនស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រសួងណាមួយនោះទេ តែកន្លងមកមានការអនុវត្ត ដោយអង្គការសង្គមស៊ីវិលដោយសហការជាមួយមន្ត្រីភូមិបាល មុនពេលដែលមានការដាក់ពាក្យស្នើសុំចុះបញ្ជីដីសមូហភាព។ ការដែលមន្ត្រីថ្នាក់ភូមិបាល តម្រូវឱ្យមានឯកសារគ្រប់គ្រាន់សម្រាប់ ដំណើរការជាពិសេសការធ្វើផែនទី ត្រូវបានគេមើលឃើញថា វាមានភាពត្រួតស៊ីគ្នាជាមួយដំណើការដែលត្រូវអនុវត្តននៅដំណាក់ការទី ៣ ទាក់ទងការចុះវាស់វែងដូចគ្នា ហេតុនេះនាំឱ្យចំណាយពេលវេលា និងធនធានច្រើន ព្រមទាំងមានលក្ខណៈស្មុគ្រស្មាញ។ ហេតុនេះហើយ ទើបបានជាសិក្ខាសាលានេះ ត្រូវបានរៀបចំឡើង ដោយផ្តោតតែទៅលើបទពិសោធន៍ជាក់ស្តែងរបស់អង្គការសង្គមស៊ីវិលដែលធ្វើការងារចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច និងបង្ហាញនូវគោលជំហររបស់ខ្លួនដើម្បីឱ្យកាន់ងាយស្រួលនិងមានប្រសិទ្ធភាព ។

## ក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធ

ច្បាប់ភូមិបាល មាត្រា ២៣ បានបង្ហាញថា ជនជាតិដើមភាគតិចជាក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលសមាជិកទាំងអស់មានការឯកភាពនៃជាតិពន្ធ សង្គម វប្បធម៌ និងសេដ្ឋកិច្ចតាមបែបប្រពៃណី និងដាំដុះលើដីដែលខ្លួនកាន់កាប់ជាសមូហភាព។ មាត្រា ២៥ ការវាស់វែងនិងកំណត់ព្រំប្រទល់ ត្រូវកំណត់ទៅតាមស្ថានភាពជាក់ស្តែងដែលសហគមននអះអាង ដោយមានការព្រមព្រៀងពីអ្នកជិតខាង និងដែលបានកំណត់ក្នុងនីតិវិធីនៃច្បាប់នេះ និងអនុក្រឹត្យពាក់ព័ន្ធ។

ច្បាប់ស្តីពីព្រៃឈើឆ្នាំ ២០០២ ត្រង់មាត្រា ៤១ រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិប្រគល់ផ្នែកណាមួយនៃព្រៃបម្រុងទុកអចិន្ត្រៃយ៍ទៅឱ្យសហគមន៍ដែលរស់នៅក្នុង ឬជិតតំបន់សហគមន៍ព្រៃឈើ ក្រោមរូបភាព ជាព្រៃសហគមន៍។ មាត្រា ៤៤ សហគមន៍ដែលដំណើរការក្រោមកិច្ចព្រមព្រៀងព្រៃសហគមន៍ មានសិទ្ធិប្រមូលផល អនុផលព្រៃឈើក្នុងដែនព្រៃឈើតាមផែនការគ្រប់គ្រងព្រៃសហគមន៍ដែលបានកំណត់ព្រំប្រទល់ជូនដូចមានចែងក្នុងកិច្ចព្រមព្រៀងព្រៃសហគមន៍។ សហគមន៍មូលដ្ឋានមិនអាចយក ព្រៃសហគមន៍ទៅប្រើប្រាស់ ក្រោមរូបភាពជាព្រៃសម្បទាន ឬលក់ដូរ ឬផ្ទេរសិទ្ធិលើព្រៃឈើនោះឱ្យ ភាគីទីបីបានឡើយ។

ដូចគ្នា នឹងច្បាប់ព្រៃឈើដែរ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិឆ្នាំ ២០០៨ មាត្រា ២២ រដ្ឋទទួលស្គាល់និងធានាសិទ្ធិប្រើប្រាស់ជាលក្ខណប្រពៃណី និងទំនៀមទម្លាប់ ជំនឿសាសនារបស់សហគមន៍មូលដ្ឋាន និង

ជនជាតិដើមភាគតិចដែលរស់នៅក្នុងតំបន់ការពារធម្មជាតិ តែទៅលើតំបន់ប្រើប្រាស់ដោយចីរភាព និង តំបន់អភិរក្ស ដោយអនុវត្តន៍តាម គោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន។ មាត្រា ២៥ ក្រសួងមាន សិទ្ធិប្រគល់ផ្នែកណាមួយនៃតំបន់ប្រើប្រាស់ដោយចីរភាព ទៅឱ្យសហគមន៍ដើម្បីរៀបចំឱ្យ ទៅជាសហគមន៍តំបន់ការពារធម្មជាតិ។

ស្របគ្នានឹងច្បាប់ស្តីពីព្រៃឈើ និង ច្បាប់ស្តីពីតំបន់ការពារធម្មជាតិដែរ ត្រង់មាត្រាទី ៧ នៃអនុក្រឹត្យលេខ ៨៣ បញ្ជាក់ថា ចំពោះដីរដ្ឋផ្សេងទៀតដែលសហគមន៍ជនជាតិដើមភាគតិចធ្លាប់អាស្រ័យផល កន្លងមក សហគមន៍អាចបន្តប្រើប្រាស់និងអាស្រ័យផលតាមប្រពៃណីរបស់ខ្លួន តែត្រូវចុះកិច្ចព្រមព្រៀងជាមួយ ស្ថាប័នសាមីដែលមានអាណត្តិគ្រប់គ្រងដីរដ្ឋនោះ។

## បទពិសោធន៍ និងការប្រឈម

- **ជំហានដែលបានអនុវត្ត ការធ្វើផែនទីបឋមកន្លងមកដោយសង្ខេប**

**ជំហាទី១** មានគោលបំណងៈ សហគមន៍មានការចូលរួមសម្រេចចិត្តក្នុងការកំណត់ព្រំប្រទល់ភូមិឱ្យបាន ច្បាស់លាស់ និងបញ្ចៀសនូវបញ្ហាវាងភូមិជិតខាង។ ដើម្បីសម្រេចបានគោលបំណងនេះ មានការប្រជុំ ពិភាក្សាជាមួយគណៈកម្មការសហគមន៍ ចាស់ទុំភូមិតាមភូមិនីមួយៗ ពន្យល់អំពីការគូសផែនទីគូស ដោយដៃសហគមន៍ ដើម្បីកំណត់ព្រំប្រទល់ភូមិ (មិនទាន់មានព្រំប្រទល់ច្បាស់លាស់)។ បន្ទាប់មកត្រូវ ឆ្លងជាមួយអ្នកភូមិ តើមានដីប្រើប្រាស់ប៉ុន្មានកន្លែង បើមានការព្រមព្រៀងទើបឈានចូលជំហានបន្ទាប់។ គូសផែនទីព្រាងដោយដៃ ដោយមានការទទួលស្គាល់តាមរយៈផ្តិតមេដៃចាស់ទុំ និងអ្នកភូមិដែល នៅជាប់ព្រំប្រទល់លើផែនទីព្រាង។ ដំណាក់ការនេះ មានការចូលរួមពីអាជ្ញាធរភូមិផងដែរ។

**ជំហានទី២** មានគោលបំណង ធ្វើការបង្ហាញផែនទីគូសដោយដៃ ដើម្បីឱ្យភូមិជិតខាង និងឃុំបានដឹងឮ និងទទួលស្គាល់ឬ/និងធ្វើការកែតម្រូវលើផែនទីគូសដោយដៃព្រាង។ អ្នកចូលរួមមាន ក្រុមប្រឹក្សាឃុំ សាមី, ចាស់ទុំគ្រប់ភូមិ និងមេភូមិដែលជាប់ពាក់ព័ន្ធ, ការិយាល័យភូមិបាលស្រុក រដ្ឋបាលព្រៃឈើ,បរិស្ថាន, អភិបាលស្រុក, ឃុំជាប់ពាក់ព័ន្ធ និង អង្គការដៃគូ។ អង្គការដៃគូសម្របសម្រួលសហគមន៍ចុះយកចំនុចនិយាមការដើម្បីផលិតផែនទីព្រាងរួម ដើម្បីដាក់ស្នើទៅមន្ទីរដែនដីនគរូបនីយកម្មខេត្ត កំណត់ដីប្រាំប្រភេទ។ យកផែនទីព្រាងទៅប្រជុំពិគ្រោះយោបល់នៅថ្នាក់ឃុំដោយអញ្ជើញ សហគមន៍ជាប់ព្រំ អជ្ញាធរឃុំ មន្ត្រីសុរិយោដី ទៅជួយផ្តល់បច្ចេកទេស។ ម្ចាស់សហគមន៍ឡើងបង្ហាញអ្នកចូលរួមទាំងអស់ ដើម្បីឱ្យមានការព្រមព្រៀងគ្នា រួចផ្តិតមេដៃយកជាផ្លូវការពីសមាជិក និងសហគមន៍ជាប់ព្រំដោយមាន បោះត្រាពីមេឃុំទាំងអស់ដែលនៅជាប់ព្រំ។

**ជំហានទី៣** សហគមន៍ដាក់ពាក្យស្នើទៅមន្ទីររៀបចំដែនដីនគរូបនីយកម្មខេត្ត តាមរយៈភូមិបាលស្រុកសុំកិច្ចសហការចុះចុច GPS កំណត់ដី ៥ ប្រភេទ ដោយយោងទៅលើផែនទីព្រាងដែលបានផលិតដោយអង្គការដៃគូ និងសហគមន៍។ យកផែនទីព្រាង ទៅធ្វើផែនការដើម្បីចុះទៅយកនិយាមការដោយប្រើជីភីអេស និងធ្វើដីប្រាំប្រភេទ ហើយយកឱ្យអ្នកជំនាញទៅចុះក្នុងប្រព័ន្ធដើម្បីចេញជាផែនទីបឋមដោយមានរង្វាស់ខ្នាតត្រឹមត្រូវ និង ដោយយោងទៅលើផែនទីព្រាងដែលបានផលិតដោយអង្គការដៃគូ និងសហគមន៍។ ដីទាំងនោះចែកចេញជាដីជាក់លាក់តាមផ្នែកនីមួយៗដូចជា ដីអារក្ស ដីលំនៅដ្ឋាន ។ល។

- **ការប្រឈមសំខាន់ៗ**

*កត្តាច្បាប់ និងបច្ចេកទេស* អនុក្រឹត្យ៨៣ និង ១១៨ ហាក់មិនឆ្លុះបញ្ចាំងពីស្ថានភាពជាក់ស្តែងរបស់សហគមន៍ដូចជាប្រពៃណីរបៀបរបបរស់នៅ (ជាក់ស្តែង ព្រៃតម និងព្រៃកប់សព អាចមានទំហំធំជាងច្បាប់កំណត់) តែក៏មានសហគមន៍មួយចំនួន ធ្វើការទាមទារនូវវិសាលភាពដែនសហគមន៍សម្រាប់យកមកចុះបញ្ជីដីសមូហភាព ហួសកំណត់ និងមិនច្បាស់លាស់ដែរ។

លើសពីនេះទៀត ការចុះបញ្ជីដីសមូហភាពសហគមន៍ជាប់ពាក់ព័ន្ធ ដែលនាំឱ្យមានការពិបាកសម្រេចចិត្តជាពិសេស ជាមួយដីសម្បទានសេដ្ឋកិច្ច និងតំបន់ការពារ ដែនជម្រក និងដីបម្រុងទុកអចិន្ត្រៃរបស់រដ្ឋ ដោយសារពុំទាន់មានការបែងចែកជាតំបន់ (ឧ. តំបន់សហគមន៍ តំបន់ប្រើប្រាស់ដោយចីរភាព តំបន់អភិរក្ស និង តំបន់ស្នូលជាដើម)។ សព្វថ្ងៃនេះ មាន១០ សហគមន៍ជនជាតិដើមភាគតិចដែលស្ថិតក្នុងតំបន់ត្រួតស៊ីគ្នាជាមួយក្រសួងបរិស្ថាន និងក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ដែលមិនទាន់បានដោះស្រាយនៅឡើយ។ ដោយឡែកនៅសហគមន៍ក្នុងខេត្តរតនគិរី ការចុះបញ្ជីហាក់ដូចជាបានលឿនដោយសារការកំណត់យកតាមផែនទីគម្របព្រៃឈើឆ្នាំ ២០០២ ពោលគឺមិនសូវមានព្រៃនៅសល់ច្រើននោះទេ។ ដូច្នេះយោងតាមការជជែកជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទើបធ្វើឱ្យគេចុះបានលឿនតែក្នុងរយៈពេលប្រហែល ៦ខែ បើធៀបជាមួយនឹងការចុះរយៈពេលជាទូទៅរហូតដល់ទៅ ២ ឆ្នាំ។

បញ្ហាទំនាស់ព្រំប្រទល់ជាមួយសហគមន៍ជិតខាង ក៏ត្រូវបានគេលើកឡើងជាច្រើនដែរ ដែលជាការពន្យានូវលទ្ធភាពជំរុញឱ្យការចុះបានលឿន ក្រៅពីបញ្ហាពាក់ព័ន្ធជាមួយដីក្រុមហ៊ុន និងដីរដ្ឋផ្សេងទៀតដូចបានលើកខាងលើ។ ទន្ទឹមហ្នឹងនេះដែរ គេពុំឃើញមានយន្តការឬគោលការដោះស្រាយទំនាស់សហគម

ន៍ចុះបញ្ជីដីសមូហភាពច្បាស់លាស់ សម្រាប់ឱ្យសហគមន៍ ឬអ្នកពាក់ព័ន្ធអាចពឹងអាស្រ័យ ក្នុងពេលកំណត់ជាក់លាក់ណាមួយនោះដែរ។

*ចំពោះកត្តាសេដ្ឋកិច្ចនិងសង្គមវិញ* មានការលើកឡើងថា សហគមន៍ត្រូវបានអ្នកមានអំណាច ឬអ្នកមានលទ្ធភាពពីក្នុងសហគមន៍ និងមកពីខាងក្រៅ ធ្វើការញុះញង់ឱ្យបោះបង់ការចុះបញ្ជីដីសមូភាព ព្រោះវាដាក់កំហិតចំពោះ ការប្រើប្រាស់ជាប្រយោជន៍ផ្សេងៗជាលក្ខណៈបុគ្គល ឬគ្រួសារ ក្នុងខណៈពេលដែលតម្រូវការប្រើប្រាស់ទាំងផលិតកម្ម និងមិនផលិតកម្ម មានការកើនឡើងជាលំដាប់។

*ដោយឡែកចំពោះការយល់ដឹង និងការចូលរួម* មានការលើកឡើងថា បញ្ហាអវត្តមានសាមីខ្លួនឬតំណាងក្នុងដំណើរការចុះបញ្ជីដែលនាំឱ្យមានការរាំងស្ទះ ពិបាកសម្រេចចិត្ត ឬយឺតយ៉ាវក្នុងការគូសផែនទីព្រាង (អ្នកដែលអវត្តមានរួមមាន ក្រុមហ៊ុននៅជាប់ព្រំ សមាជិកសហគមន៍ និងសមាជិកភូមិជាប់ព្រំ មេឃុំ ឬមេភូមិ)។ បញ្ហាអវត្តមានរបស់សមាជិកសហគមន៍ អាចបណ្តាលមកពីការមិនយល់ច្បាស់ពីអត្ថប្រយោជន៍ផែនទីបឋម ឬការមិនបានផ្សព្វផ្សាយទូលំទូលាយ។ លើសពីនេះទៅទៀតការសិក្សារបស់មន្ត្រីពាក់ព័ន្ធនិងអាជ្ញាធរ ក៏មិនសូវបានចុះទៅដល់ទីតាំងមូលដ្ឋានជាក់ស្តែងផងដែរ។

## ជំហរដែលយើងខ្ញុំស្នើឡើង

## យោបល់ដែលបានស្នើឡើងទូទៅ

- ការចុះបញ្ជីដីជាប្រព័ន្ធ គួរកុំទាន់ចាប់ផ្តើមអនុវត្ត នៅតំបន់ជនជនជាតិដើមភាគតិច ដើម្បីជៀសវាងការងាករេ របស់សហគមន៍ជនជាតិដើមភាគតិច មកយកការចុះបញ្ជីជាឯកត្តជនវិញ។ ជាលទ្ធផល សហគមន៍អាចនឹងមានការរងគ្រោះ ដោយសារតែមិនអាចគ្រប់គ្រងដីរបស់ខ្លួនបានតាមការចាត់ចែងដូចជា ការលក់ដូរ ឬការរំលោភបំពានផ្សេងៗ។
- ក្រៅពីការកំណត់លើការចុះបញ្ជីដី ៥ប្រភេទ គួរផ្សព្វផ្សាយឱ្យសហគមន៍យល់ច្បាស់អំពី ភាពចាំបាច់នៃការធ្វើកិច្ចព្រមព្រៀងដោយឡែកទាក់ទង CF និង CPA ជាមួយស្ថាប័នពាក់ព័ន្ធ តាមរូបភាពសហគ្រប់គ្រងរវាងសហគមន៍ និងស្ថាប័នរដ្ឋដែលពាក់ព័ន្ធដូចជា ក្រសួងបរិស្ថាន ឬក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។
- ពន្លឿនការកំណត់តំបន់គ្រប់គ្រង (Zoning) ដោយមានការចូលរួមពេញលេញ យោងតាមអនុក្រឹត្យលេខ ៨៣ ស្តីពីនីតិវិធីចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច និង ១១៨ ស្តីពីការគ្រប់គ្រងដីរដ្ឋ។ ការកំណត់តំបន់គឺ មានគោលបំណងជៀសវាងការមានទំនាស់ក្នុងការប្រើ

ប្រាស់និងគ្រប់គ្រងធនធានធម្មជាតិ នៅក្នុងតំបន់ការពារ បង្កើនប្រសិទ្ធភាពនៃការអភិរក្ស ព្រមទាំងបង្កើននូវផលប្រយោជន៍សេដ្ឋកិច្ចសង្គម និងប្រព័ន្ធអេកូឡូស៊ី។

- ការប្រើប្រាស់យុទ្ធសាស្ត្រស្បែកខ្លា ក្នុងការចុះបញ្ជីដីសមូហភាព ដើម្បីជៀសវាងការមានទំនាស់រវាងព្រំប្រទល់សហគមន៍ឬភូមិ ឬវិសាលភាពធំជាងនេះ។ ការធ្វើដូចនេះ នាំឱ្យសហគមន៍អាចដាក់បញ្ចូលដីរបស់ខ្លួនដែលស្ថិតនៅក្នុងភូមិឬឃុំដទៃ។ វាជាការបាត់បង់គួរឱ្យចាប់អារម្មណ៍ ព្រោះមានករណីខ្លះ ដីសហគមន៍ត្រូវបាត់បង់ ដោយសារដីនោះត្រូវបានពុះចែកដោយព្រំប្រទល់ខេត្ត ដូចជាករណីនៅខេត្តក្រចេះ និងមណ្ឌលគិរីជាដើម។

## យោបល់ដែលបានស្នើឡើងជាក់លាក់

- ខាងក្រោមនេះជាជំហានជាក់លាក់ដែលស្នើឡើងតាមលំដាប់លំដោយ ដើម្បីបង្កើនល្បឿនចុះបញ្ជី ដោយមានបង្ហាញពីអ្នកទទួលខុសត្រូវ និងអ្នកចូលរួមតាមជំហាននីមួយៗ។

| ជំហានដែលគួរធ្វើតាមលំដាប់ | អ្នកដែលគួរទទួលខុសត្រូវ | អ្នកដែលគួរចូលរួម |
|---|---|---|
| ក្រោយពីទទួលស្គាល់ស្វ័យអត្តសញ្ញាណរួចហើយ ត្រូវចាប់ផ្តើមផ្សព្វផ្សាយដូចជា សិទ្ធិជនជាតិដើមភាគតិច ការប្រើប្រាស់ដី និងការអនុវត្តច្បាប់តឹងរឹងក្នុងការគ្រប់គ្រងដី សមូហភាព (សហគមន៍ អាជ្ញាធរភូមិ ឃុំ ស្រុក) | មន្ត្រីភូមិបាលស្រុក និងមន្ទីរដែនដី | អាជ្ញាធរភូមិឃុំស្រុក សហគមន៍ |
| ការធ្វើផែនទីក្បាលដីបឋម (sketch map) ដោយកំណត់ព្រំដីតាមទីតាំង តាមប្រភេទដី និងទំហំប្រហាក់ប្រហែល និងបញ្ជីសហគមន៍គ្រួសារដែលស្ថិតក្នុងក្បាលដីរួម (ក្រុមៗ) ដោយប្រើនិមិត្តសញ្ញា (ពណ៌) តាមប្រភេទដីសផ្សេងៗពីគ្នា។ | គណៈកម្មការសហគមន៍ បណ្តោះអាសន្ន និងចាស់ទុំ | សមាជិកសហគមន៍ អាជ្ញាធរភូមិឃុំ |
| ពិនិត្យប្រភេទដីដែលសហគមន៍បានដាក់ពាក្យថា តើដីទាំងនោះអាចនឹងជាន់ជាមួយតំបន់ការពារ ឬព្រៃបម្រុងទុកអចិន្ត្រៃដែរឬទេ? | គណៈកម្មការសហគមន៍ បណ្តោះអាសន្ន និងចាស់ទុំ | សមាជិកសហគមន៍ អាជ្ញាធរភូមិឃុំស្រុក មន្ទីរបរិស្ថាន ខណ្ឌរដ្ឋបាលព្រៃឈើ |

| | | |
|---|---|---|
| ដាក់ពាក្យស្នើសុំឱ្យចេញវិធានការការពារបណ្ដោះអាសន្នពីថ្នាក់ខេត្ត ការពារលក់ដូរដី (ផ្សព្វផ្សាយជាសាធារណៈ) ។ គួរបង្ហាញពីយន្តការដាក់បណ្ដឹង និងតាមដាន សម្រាប់សហគមន៍ទូទៅ។ | គណៈកម្មការសហគមន៍<br>បណ្ដោះអាសន្ន | ចាស់ទុំ អង្គការគាំទ្រ |
| រៀបចំលក្ខន្តិកៈ ស្នើសុំចុះបញ្ជីជានីតិបុគ្គល នៅក្រសួងមហាផ្ទៃ (ទទួលស្គាល់លក្ខន្តិកៈ និងតែងតាំងគណៈកម្មាធិការ) | មន្ត្រីអន្តរវិស័យខេត្ត ក្រសួងមហាផ្ទៃ និងគណៈកម្មការសហគមន៍បណ្ដោះអាសន្ន | ចាស់ទុំ សមាជិកសហគមន៍ អាជ្ញាធរភូមិឃុំ ស្រុកខេត្ត មន្ទីរពាក់ព័ន្ធ អង្គការគាំទ្រ |
| រៀបចំបទបញ្ញាផ្ទៃក្នុង សម្រាប់គ្រប់គ្រង ប្រើប្រាស់ និងដោះស្រាយវិវាទដីសមូហភាព | ការិយាល័យភូមិបាលស្រុកមន្ទីរ និងក្រសួងដែនដី | ចាស់ទុំ សមាជិកសហគមន៍ អាជ្ញាធរភូមិឃុំ ស្រុកខេត្ត មន្ទីរពាក់ព័ន្ធ អង្គការគាំទ្រ |
| ដាក់ពាក្យស្នើសុំចុះបញ្ជីដីសមូហភាព យោងតាមផែនទីក្បាលដីបឋមដែលមានស្រាប់ ក្រោយពីទទួលបាននីតិបុគ្គល (សជណ)។ | គណៈកម្មាធិការសហគមន៍ | មេឃុំ ភូមិបាលស្រុក |
| ក្រោយពីដាក់ពាក្យស្នើសុំចុះបញ្ជីដីសមូហភាពរួចហើយ វាជានីតិវិធីរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | |

## សេចក្ដីសន្និដ្ឋាន

ការធ្វើផែនទីក្បាលដីបឋម ឬផែនទីបឋម នៅតែមានភាពចាំបាច់ក្នុងដំណើរការចុះបញ្ជីដីសមូហភាព ហើយត្រូវបានស្នើឱ្យដាក់មកកៀកនឹងដំណាក់ការដំបូងគឺ បន្ទាប់ពីមានការទទួលស្គាល់ស្វ័យអត្តសញ្ញាណ ដោយប្រើវិធីសាមញ្ញៗដែលសហគមន៍ អាចចូលរួមធ្វើបានដូចជា ការកំណត់ព្រំដីតាមទីតាំងតាមប្រភេទដី និងទំហំប្រហាក់ប្រហែល និងបញ្ជីសហគមន៍គ្រួសារដែលស្ថិតក្នុងក្បាលដីរួម (ក្រុមៗ) ។ ធ្វើដូចនេះក៏នឹងអាចមានលក្ខណៈងាយស្រួលសម្រាប់សហគមន៍ ក៏ដូចជាភាគីពាក់ព័ន្ធបានកំណត់ អំពីធនធាន និងប្រភេទដី ដែលសហគមន៍កំពុងអាស្រ័យផល មុននឹងរៀបចំបទបញ្ញាផ្ទៃក្នុងសម្រាប់គ្រប់គ្រង និងប្រើប្រាស់។ បន្ទាប់មកចាត់ចែងឱ្យមានវិធានកាណ៍បណ្ដោះអាសន្នដោយជំរុញការអនុវត្តម៉ឺងម៉ាត់ ដើម្បីកុំឱ្យរាំងស្ទះព្រោះតែមានការផ្ទេរឬដោះដូរដី ព្រោះជាហានិភ័យមួយសំខាន់។ ការធ្វើតាមសេចក្ដីស្នើខាងលើនេះ អាចនាំមកនូវផលប្រយោជន៍ដ៏សំខាន់គឺ ដីត្រូវបានការពារតាមផ្លូវច្បាប់ និងមាន

សុវត្ថិភាពដីធ្លី ដោយសារមានវិធានការការពារបណ្តោះអាសន្ន មានសហគមន៍កាន់តែច្រើនដែលអាចដាក់ពាក្យ និងទទួលបានប័ណ្ណកម្មសិទ្ធិសមូហភាព ចំណេញពេលវេលា និងថវិកា និង សហគមន៍មានទំនុកចិត្ត និងចូលរួម។ ដោយឡែកយន្តការណ៍សម្របសម្រួលរវាងស្ថាប័នដែលមានតំបន់ត្រួតស៊ីគ្នាជាមួយសហគមន៍ គួរត្រូវបានបង្កើតឡើង ដើម្បីពិភាក្សារកច្រកចេញដែលបានជាប្រយោជន៍ទៅវិញទៅមក រួចជាមួយការបង្កើនការយល់ដឹងអំពីការចុះបញ្ជីប្រភេទដីផ្សេងទៀត (សហគន៍ព្រៃឈើ ឬព្រៃការពារសហគមន៍ ដែលជាជម្រើសតាមទំរង់សហគ្រប់គ្រងរវាងសហគមន៍ និងក្រសួងពាក់ព័ន្ធ។

**បញ្ជីឈ្មោះស្ថាប័នដែលបានចូលរួម**

១. ក្រសួងអភិវឌ្ឍន៍ជនបទ MRD
២. ក្រសួងមហាផ្ទៃ MoI
៣. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ MLMUPC
៤. វេទិការនៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា NGO Forum
៥. អង្គការ Diakonia
៦. អង្គការ ជំនួយប្រជាពលរដ្ឋណ័រវេ NPA
៧. អង្គការ HEKS
៨. ការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា OHCHR
៩. អង្គការ សមាគមខ្មែរលើរតនគិរី Highlander Association
១០. អង្គការពន្លកខ្មែរ PKH
១១. អង្គការ មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ CLEC
១២. អង្គការ ភូមិខ្ញុំ MVi
១៣. អង្គការ WCS
១៤. អង្គការ គាំទ្រសហគមន៍ជនជាតិដើមភាគតិច ICSO
១៥. អង្គការ អភិវឌ្ឍន៍និងភាពជាដៃគូក្នុងសកម្មភាព DPA
១៦. អង្គការ FLO
១៧. អង្គការ SVC
១៨. អង្គការ ADIC (សម្របសម្រួល និងធ្វើរបាយការណ៍)